ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី

# ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.)

ECONOMIC, SOCIAL AND CULTURAL COUNCIL (ECOSOCC)







# វិភាគស្ថានភាព

# សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ប្រចាំខែកុម្ភៈ ឆ្នាំ២០២០

# វិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា
# ប្រចាំខែកុម្ភៈ ឆ្នាំ២០២០*

របាយការណ៍វិភាគនេះជាលទ្ធផលនៃកិច្ចប្រជុំចង្អៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) លើស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ដែលបានប្រព្រឹត្តទៅនាថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០។ ឯកឧត្តមទេសរដ្ឋមន្ត្រី **យឹម ឆាយលី** ប្រធានក.ស.វ. បានណែនាំឯកឧត្តម **នរ៉ាណាឫទ្ធិ អានន្ទយ៉ាត** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អនុប្រធានក.ស.វ.និងជាប្រធានក្រុមការងារវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ឲ្យដឹកនាំកិច្ចប្រជុំពិភាក្សាក្រុមការងារវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីធ្វើការវិភាគលម្អិតដោយពឹងផ្អែកលើមូលដ្ឋានព័ត៌មាន ទិន្នន័យ និងការផ្តល់យោបល់មួយចំនួនតាមរយៈតេលេក្រាមពីក្រសួងស្ថាប័នពាក់ព័ន្ធ មុនពេលប្រជុំ។

## ១. ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងអត្រាប្តូរប្រាក់ (តារាង១)

➡ នាខែកុម្ភៈ ឆ្នាំ២០២០សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ថយចុះ០,១% ធៀបនឹងខែមុនប៉ុន្តែ កើនឡើង២,៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
|---|---|---|---|
| ភោជនីយដ្ឋាន: | +៤,៣% | ប្រេងសាំង | +៨,៧% |
| ម្ហូបអាហារ: | +៣,២% | ត្រីស្រស់: | +៧,០% |
| ម្ហូបអាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង | +៣,២% | អង្ករ: | +៤,១% |
| ការដឹកជញ្ជូន | +៣,០% | ឧស្ម័ន: | +៣,១% |
| ទំនិញ និងសេវាកម្មផ្សេងៗ | +៣,០% | សាច់មាន់: | +៣,០% |
| ការសិក្សា: | +២,៧% | ផ្លែឈើ: | +២,៦% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | +២,២% | សាច់គោ: | +២,៥% |
| សំលៀកបំពាក់ និងស្បែកជើង: | +១,៥% | ប្រេងម៉ាស៊ូត | +២,៣% |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេងទៀត: | +០,៩% | | |

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១៨–២០២០

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មីនា P | មេសា P | ឧសភា P | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០២០ | ដូចគ្នាឆ្នាំមុន | ៣,៦% | ២.៧% | ២,៣% | ២,១% | ២,២% | | | | | | | | |
| | មុន | ០,៥% | -០,១% | -០,១% | ០,២% | ០។៣% | | | | | | | | |
| ២០១៩ | ដូចគ្នាឆ្នាំមុន | ១,៥% | ២,០% | ២,២% | ២,១% | ២,០% | ១,៤% | ២,២% | ២,១% | ១,៧% | ១,៣% | ១,៨% | ៣,១% | ១,៩% |
| | មុន | -០,០២% | ០,៨% | ០,៣% | ០,៣% | ០,២% | -០,៤% | ០,៥% | ០,៦% | -០,០៣% | -០,១% | ០,១% | ០,៨% | |
| ២០១៨ | ដូចគ្នាឆ្នាំមុន | ២,០% | ២,៣% | ២,៣% | ២,៤% | ២,៩% | ២,៩% | ២,៣% | ២,៦% | ២,៦% | ៣,១% | ២,៥% | ១,៦% | ២,៥% |
| | មុន | ០,១% | ០,៤% | ០,០៤% | ០,៥% | ០,៣% | ០,១% | -០,៣% | ០,៧% | ០,៣% | ០,៣% | -០,៣% | ០,១% | |

**P:** តួលេខខែមីនា ខែមេសា និងខែឧសភា ២០២០ ជាតួលេខព្យាករណ៍ (តាមវិធីសាស្ត្រ DECOMPOSITION)

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១.១. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់




តារាង១.៣. អត្រាប្តូរប្រាក់

| *ប្រភេទ* | *កុម្ភៈ ២០២០* | *មករា ២០២០* | *កុម្ភៈ ២០១៩* | *ប្រភេទ* | *កុម្ភៈ ២០២០* | *មករា ២០២០* | *កុម្ភៈ ២០១៩* |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤០៧០៛/១$ | ៤០៥០៛/១$ | ៤០០៣៛/១$ | **បាត/ដុល្លារ** | ៣១,៧បាត/១$ | ៣១,២បាត/១$ | ៣១,៤បាត/១$ |
| **៛/បាត** | ១២៩៛/១បាត | ១៣០៛/១បាត | ១២៧៛/១បាត | **ដុង/ដុល្លារ** | ២៣២៣៨ដុង/១$ | ២៣១៧៩ដុង/១$ | ២៣១៩៨ដុង/១$ |
| **៛/ដុង** | ០,១៧៥៛/១ដុង | ០,១៧៥៛/១ដុង | ០,១៧៣៛/១ដុង | **យ៉ន់/ដុល្លារ** | ៧,០ យ៉ន់/១$ | ៦,៩ យ៉ន់/១$ | ៦,៧ យ៉ន់/១$ |

## ២. ស្ថានភាពថវិកាជាតិ( តារាង២ )

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងខែកុម្ភៈ ឆ្នាំ២០២០ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម:

**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន ១ ៨៨០,៩ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៤៧០,២ លានដុល្លារ (*មធ្យមប្រចាំខែ ៨៧,១% នៃផែនការ*) ក្នុងនោះចំណូលចរន្តចំនួន ១ ៨៧៧,៥ ប៊ីលានរៀល គិតជាដុល្លារអាមេរិក ស្មើ ៤៦៩,៤ លានដុល្លារ (*មធ្យមប្រចាំខែ ៨៨,៧% នៃផែនការ*) និងចំណូលមូលធនមានចំនួន ៣,៤ ប៊ីលានរៀល ។

➢ ចំណូលថវិកាជាតិ កើនឡើង១៣,៧% ធៀបនឹងខែមុននិង កើនឡើង៣៣,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន ១ ៤៥៩,៩ ប៊ីលានរៀល ថយចុះ១,៧% ធៀបនឹងខែមុនប៉ុន្តែ កើនឡើង១៤,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន (តាមតួលេខរតនាគារជាតិ)។

✓ចំណូលមិនមែនសារពើពន្ធ មានចំនួន ៤១៧,៦ ប៊ីលានរៀលកើនឡើង១៤៧,៥% ធៀបនឹងខែមុន និង កើនឡើង២៣១,០% ធៀបនឹងខែដូចគ្នាឆ្នាំមុន (តាមតួលេខរតនាគារជាតិ)។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៨-២០២០

(ប៊ីលានរៀល)



**តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| **ចំណូលសារពើពន្ធ**<br>(ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | **ចំណូលមិនមែនសារពើពន្ធ**<br>(តាមតួលេខ រតនាគារជាតិ)<br>(ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: :-១,៥%<br>(អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | (+១០,៣%) | ➢អាជ្ញាបណ្ណក្នុងស្រុក : -៩០,៣% | (កើនកំហុគ) |
| | | ➢ ផលទុននៃសកម្មភាពទេសចរណ៍: -៣២,៥% | (-៤០,០%) |
| ➢ ចំណូលពន្ធដារ: +១,៧%<br>(អគ្គនាយកដ្ឋានពន្ធដារ) | (+៦,៩%) | ➢សម្បទានរ៉ែ: +៤១,០% | (+៥៣,៨%) |
| | | ➢ អាកាសចរណ៍ស៊ីវិល: កើនកំហុគ | (+២៣,០%) |

**២.២. ចំណាយថវិកាជាតិ** : អនុវត្តបាន ១ ៩៤៤,៥ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៤៨៦,១ លានដុល្លារ(*មធ្យមប្រចាំខែ ៥៤,៧% នៃផែនការ*) ក្នុងនោះ ចំណាយចរន្តចំនួន ១ ៥៨០,៤ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៣៩៥,១ លានដុល្លារ (*មធ្យមប្រចាំខែ ៨០,៦% នៃផែនការ*) និងចំណាយមូលធនមានចំនួន ៣៦៤,០ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៩១,០ លានដុល្លារ(*មធ្យមប្រចាំខែ ១៨,៩% នៃផែនការ*) (តាមតួលេខ រតនាគារជាតិ)។

➢ចំណាយថវិកាជាតិកើនឡើង១១៨,៧% ធៀបនឹងខែមុននិង កើនឡើង៩១,៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ ចំណាយចរន្តកើនឡើង៨៧,៨% ធៀបនឹងខែមុននិងកើនឡើង៧៦,៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះ មានឱនភាពចំនួន ៦៣,៦ ប៊ីលានរៀល គិតជាដុល្លារ អាមេរិក ស្មើ ១៥,៩ លានដុល្លារ (តួលេខ រតនាគារជាតិ)។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៧-២០១៩
(ប៊ីលានរៀល)




## ៣. ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់ (តារាង៣)

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែកុម្ភៈ ឆ្នាំ២០២០ មានលក្ខណៈដូចខាងក្រោម:

➢រូបិយវត្ថុM $_2$ មានចំនួន ១២២ ៩១២ ប៊ីលានរៀល មានការកើនឡើង១,៥%ធៀបនឹងខែមុននិងកើនឡើង ១៨,៦%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការកើនឡើងM$_2$** ក្នុងខែនេះ ជារួមបណ្តាលមកពី ការកើនឡើងនៃ រូបិយវត្ថុក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើ២,៤% ប្រាក់បញ្ញើចរន្ត១,៣% និងប្រាក់បញ្ញើផ្សេងទៀត១,៤%។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែកុម្ភៈ ឆ្នាំ២០២០



➢ក្នុងខែនេះ ប្រាក់រៀលនៅក្នុង និងក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើរមានចំនួន១៥,៧% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន៨៤,៣% នៃរូបិយវត្ថុ$M_2$។

តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០២០

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅស្ថាប័នទទួលប្រាក់បញ្ញើ | ១៥,៦% | ១៥,៧% | | | | | | | | | | |
| រូបិយបណ្ណបរទេសនៅក្នុងធនាគារ | ៨៤,៤% | ៨៤,៣% | | | | | | | | | | |

ក្រាហ្វ៣.២.បម្រែបម្រួលសមាសធាតុរូបិយវត្ថុខែកុម្ភៈ ២០២០: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




តារាង៣.៣.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| ផ្តល់ដោយ | កុម្ភៈ ២០២០ | មករា ២០២០ | កុម្ភៈ ២០១៩ |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ប៊ីលានរៀល)<br>ក្នុងនោះ: ជារៀល | ១១០ ៩៦៥<br>១១ ៩៣៩ | ១០៧ ៥៩៤<br>១១ ៥១៣ | ៨៦ ៨៤០<br>៣ ៩៨១ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ប៊ីលានរៀល) | ២៩ ៩៣០ | ២៩ ៣១៤ | ២៣ ២០៦ |
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៤,៧១% | ៤,៥៩% | ៥,១៤% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៣,៥៣% | ៣,៧០% | ៣,៣៦% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១០,៥២% | ១០,៦៤% | ១២,៣០% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ៨,២៤% | ៨,១៨% | ៨,៣១% |
| កម្ចីជារៀលនៅហត្ថកសិករ | ១៧,៧% | ១៨,០% | ១៨,០% |
| កម្ចីជារៀលនៅអម្រឹត | ១៧,១% | ១៨,០% | ១៨,០% |
| កម្ចីជារៀលនៅប្រាសាក់ | ១៧,៥% | ១៧,០% | ១៧,៥% |

## ៤. ស្ថានភាពកសិកម្ម ឧស្សាហកម្ម ថាមពល សេវាកម្ម និងវប្បធម៌ (តារាង៤)

➡ក្នុងខែកុម្ភៈ ឆ្នាំ២០២០ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➢**កសិកម្ម**:

✓នេសាទសម្រេចបាន ៥៩,៦ ពាន់តោន កើនឡើង១៤,៧% ធៀបនឹងខែមុននិង កើនឡើង៧,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➤**រ៉ែ និងថាមពល**:

✓អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ៩៦៥,៧ GWh មានការថយចុះ៤,៦% ធៀបនឹងខែមុនប៉ុន្តែ កើនឡើង ៩,៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ៖

- អគ្គិសនីផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន ៥៧,១ GWh មានការថយចុះ២០,៥% ធៀបនឹងខែមុន និងថយចុះ ៦៣,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- អគ្គិសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន ៤១១,១ GWh មានការថយចុះ១,៩% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៨,៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- អគ្គិសនីដែលនាំចូលពីប្រទេសជិតខាងដោយ EDCមានចំនួន៤១១,៦ GWh មានការថយចុះ២,៩% ធៀបនឹងខែមុនប៉ុន្តែ កើនឡើង៦៩,៣%ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- និងអគ្គិសនីផ្គត់ផ្គង់ដោយប្រភពផ្សេងទៀតមានចំនួន ៨៥,៩ GWh មានការថយចុះ១២,0% ធៀបនឹងខែមុន និង ថយចុះ១៦,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➤**ឧស្សាហកម្ម**:

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៣៥៥,៣ លានដុល្លារ មានការ ថយចុះ៤២,៦% ធៀបនឹងខែមុន និង ថយចុះ៣៨,៩%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៤.១. ការចុះបញ្ជីរោងចក្រនិងឧស្សាហកម្មធុនតូច និងសិប្បកម្មនៅក្រសួងឧស្សាហកម្ម

| *ប្រភេទ* | *ចំនួន—កុម្ភៈ ២០២០* | *ចំនួន—មករា ២០២០* | *ចំនួន—កុម្ភៈ ២០១៩* |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ២១ | ៣៦ | ១៣ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១ ៧៨១ | ១៧៦៤ | ១ ៥៥៨ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ៥ | ១៣ | ៣ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ១០ | ១៤ | ៥ |

➤**សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ២ ២៨៨,១ ពាន់ម² មានការកើនឡើង២២,១% ធៀបនឹងខែមុន និងកើនឡើង ១១៦,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង ១ ១២៧,២ លានដុល្លារមានការកើនឡើង២៩,៧% ធៀបនឹងខែមុន និងមានការកើនឡើង១០៣,៤% បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| *ប្រភេទ* | *ពាន់ម² — កុម្ភៈ ២០២០* | *ពាន់ម² — មករា ២០២០* | *ពាន់ម² — កុម្ភៈ ២០១៩* |
|---|---|---|---|
| ▪ លំនៅឋាន | ១ ២៩៩,៨ | ៧៥៤,៧ | ៤២៥,៣ |
| ▪ ឧស្សាហកម្ម | ១០៨,០ | ២៨៤,៨ | ១៥៣,៨ |
| ▪ពាណិជ្ជកម្ម | ៤៣៧,៤ | ៧៦៩,៦ | ៤៦៣,៦ |
| ▪ ទេសចរណ៍ | ១១៦,៩ | ៥៣,៨ | ៦,១ |
| ▪ផ្សេងៗ | 0,0 | 0,0 | ១,៦ |
| អនុញ្ញាតសរុប | ២ ២៨៨,១ | ១ ៨៧៤,៣ | ១ 0៥៦,២ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺលំនៅឋាន ៥៦,៨% និងពាណិជ្ជកម្ម ១៩,១% នៃផ្ទៃក្រឡាសរុប។

## ➢សេវាកម្ម

តារាង៤.៣.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន —កុម្ភៈ ២០២០ | ចំនួន—មករា ២០២០ | ចំនួន—កុម្ភៈ ២០១៩ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៦១៥ | ៦៨២ | ១ ៤៧៩ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ២៥ | ២៧ | ១៧ |
| សហគ្រាសដែលបានចុះបញ្ជីពន្ធដារ | ៧៧៨ | ៥៤៧ | ៥៣៨ |

## ➢ការងារ

តារាង៤.៤. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់— កុម្ភៈ ២០២០ | នាក់— មករា២០២០ | នាក់— កុម្ភៈ ២០១៩ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបរនិងការងារ) | ១ ៤៣៧ | ១ ១៩៧ | ១ ៣៦៧ |
| អ្នកទទួលបានការងារធ្វើតាមរយៈ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងទីភ្នាក់ងារជ្រើសរើសឯកជន | ៣១ ៩០៧ | ២១ ៤៤៥ | ២២ ៣៥០ |
| អ្នកទទួលបានការងារក្នុងប្រទេស | ២៥ ៦៦៨ | ១៦ ៩៧៦ | ១៦ ៧៧៦ |
| អ្នកទទួលបានការងារក្រៅប្រទេស | ៦ ២៣៩ | ៤ ៤៦៩ | ៥ ៥៧៤ |

## ➢វិនិយោគ

តារាង៤.៥.គម្រោងវិនិយោគអនុញ្ញាតដោយ ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | កុម្ភៈ ២០២០ | មករា ២០២០ | កុម្ភៈ ២០១៩ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ៨៧០,៨ | ៩២,៧ | ១ ៨៦៦,៤ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ២០,២ | ០,០ | ០,០ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ១២៥,៥ (១០,៩) | ៩២,៧ (៤៦,០) | ២៤០,៨ (៦៧,៤) |
| វិស័យទេសចរណ៍ | ១៣៣,០ | ០,០ | ១ ៦១៨,៨ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ៥៩២,១ | ០,០ | ៦,៨ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ៣២ | ១៧ | ៤១ |
| បង្កើតការងារ (ពាន់នាក់) | ២០,៦ | ១២,២ | ៥៣,៧ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប២កំពង់ផែ) មានចំនួន ៧០៩,៤ ពាន់តោន មានការថយចុះ២៨,៩% ធៀបនឹងខែមុននិងថយចុះ២,០% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ក្នុងនោះ:

តារាង៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | |
|---|---|
| ▪ កំពង់ផែភ្នំពេញ: -២២,៩% (+៧,៧%) | ▪ កំពង់ផែកំពង់សោម: -៣២,៥% (-៧,៧%) |

## ➢ការចុះបញ្ជី និងចរាចរណ៍

តារាង៤.៧.ការចុះបញ្ជីម៉ូតូ រថយន្ត និងគ្រោះថ្នាក់ចរាចរណ៍

| ប្រភេទ | ចំនួន—កុម្ភៈ ២០២០ | ចំនួន—មករា ២០២០ | ចំនួន—កុម្ភៈ ២០១៩ |
|---|---|---|---|
| ចំនួនម៉ូតូបានចុះបញ្ជី (ពាន់គ្រឿង) | ៥៣,៥ | ៤២,៨ | ៤៩,២ |
| ចំនួនរថយន្តគ្រប់ប្រភេទបានចុះបញ្ជី(ពាន់គ្រឿង) | ១០,០ | ១១,២ | ៧,៣ |
| ចំនួនគ្រោះថ្នាក់ចរាចរណ៍ (លើក) | ២៧៨ | ៣៥៨ | ៣៦២ |

## ➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ២១,៥ | -១៥,៦% | +២០,២% |
| ក្នុងនោះទទួល | ២,៧ | +៥,២% | +២០,៨% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ៨៣,៩ | -១៥,៣% | -១៥,៤% |
| ក្នុងនោះទទួល | ៤៤,១ | -១៦,៧% | -១៤,២% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ១ ១៩១,៩ | -៤,៧% | -២៧,៩% |
| ក្នុងនោះហៅចូល | ៤៤០,៤ | +០,៤% | -៦,៣% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ៣ ៦២៩,៣ | -១៤,១% | -៤៥,៧% |
| ក្នុងនោះហៅចូល | ៣ ៥៦៧,៩ | -១៤,៧% | -៤៦,២% |

## ➢ ធ្វើដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍

តារាង៤.៨.អ្នកដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍

| ប្រភេទ | ចំនួន(ពាន់នាក់) | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១៥,៦ | -៣០,៣% | -៣៧,៩% |
| ភ្ញៀវទេសចរបរទេសទិញប័ណ្ណទស្សនាអង្គរ | ១១៨,៩ | -៤៦,៦% | -៥៦,៥% |
| ភ្ញៀវទេសចរចូលទស្សនា រមណីយដ្ឋានព្រះវិហារ | ១៣,០ | +៣០,៤% | +៩,៥% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៧៥,៩ | -៤០,៨% | -៤៣,៩% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៤៦៣,៧ | -៤៧,២% | -៥០,៣% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ១០៦,១ | -៣០,៤% | -២៧,៥% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ៣៨៣,៩ | -២៩,៩% | -៣៥,៨% |
| ✓ តាមផ្លូវអាកាស | ២១០,៥ | -៣៦,៦% | -៥២,១% |
| ✓ តាមផ្លូវគោក និងទឹក | ១៧៣,៤ | -១៩,៧% | +៩,៦% |

# ៥. ស្ថានភាពជញ្ជីងពាណិជ្ជកម្ម(តារាង៥)

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាខែកុម្ភៈ ឆ្នាំ២០២០ មានចំនួន ៥ ០៦៩,៧ ប៊ីលានរៀល (ស្មើនឹង ១ ២៦៧,៤ លានដុល្លារ ស.រ.អា.)ថយចុះ៣៦,៨% ធៀបនឹងខែមុនប៉ុន្តែកើនឡើង០,៤%ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ៖

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | -១៤,៦% | -២,៣% | រថយន្តសរុប (ប៊ី.ល.រ) | -១១,៤% | +២៣,៧% |
| ប្រេងម៉ាស៊ូត | +២៨,២% | +២០,៥% | រថយន្តសរុប (គ្រឿង) | -១,៤% | +៣០,១% |
| ឧស្ម័ន | +៥២,១% | +៤៦,៨% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | +៤៥,៥% | -៧,១% |

| | | | | | |
|---|---|---|---|---|---|
| អគ្គិសនីនាំចូលដោយEDC | -២,៩% | +៦៩,៣% | ម៉ូតូ (គ្រឿង) | +២១,២% | +៤,៩% |
| ដែកសំណង់ | -១៨,៣% | -៥៩,0% | អង្ករ | -១៥,៧% | +៤១,៥% |
| ស៊ីម៉ង់ត៍ | +៣២,៧% | +១១៥,0% | ផ្លែឈើនិងបន្លែ | -៨៥,៣% | +១១,៩% |
| គ្រឿងអេឡិចត្រូនិក | -៩0,0% | -៨១,៦% | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | -៥៤,៨% | -៣១,១% |
| ថ្នាំកសិកម្ម | -៦៥,១% | +៩,២% | | | |

➡ **ការនាំចេញ** ខែកុម្ភៈ ឆ្នាំ២០២០ មានចំនួន **៥ 0១១,៩** ប៊ីលានរៀល ស្មើនឹង **១ ២៥៣,0** លានដុល្លារ ស.រ.អា. (៩៨,៩% នៃការនាំចូល) មានការថយចុះ៥,៣% ធៀបនឹងខែមុន និងកើនឡើង២៦,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ***ទំនិញ*** | ***%Δធៀបនឹងខែមុន*** | ***%Δធៀបនឹងខែដូចគ្នាឆ្នាំមុន*** | ***ទំនិញ*** | ***%Δធៀបនឹងខែមុន*** | ***%Δធៀបនឹងខែដូចគ្នាឆ្នាំមុន*** |
|---|---|---|---|---|---|
| ផលិតផលឈើកែឆ្នៃ | +១៩,៣% | +៤៩,៥% | ផលិតផលនេសាទ | +២,៦% | -៣៤,៦% |
| វាយនភណ្ឌនិងស្បែកជើង | -១៣,0% | +១៥,៤% | កៅស៊ូ | -0,៥% | -៩,0% |
| អង្ករ | +៣0,៧% | +៥៦,៦% | | | |

## រាជធានីភ្នំពេញនាពេលរាត្រី




ក្រុមការងាររៀបចំរបាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

អាសយដ្ឋាន: អគារមិត្តភាព លេខ៨១ មហាវិថីសហព័ន្ធរុស្ស៊ី ខណ្ឌ៧មករា រាជធានីភ្នំពេញ

ទូរស័ព្ទ: ០៨៥ ៧៧៧ ៩៨០ / ០១២ ៦៦២ ៣១៦ ទូរសារ: ០២៣ ២២១ ៨៩០

Email: chyanit168@gmail.com  /  mamsarith@yahoo.com